

Department of Public Health
CITY OF PHILADELPHIA

# រក្សាសុវត្ថិភាពបង្ការជំងឺផ្តាសាយបក្សី៖ ព័ត៌មានសម្រាប់មជ្ឈមណ្ឌលអប់រំកុមារតូចៗ និងអ្នកថែទាំ

ជំងឺផ្តាសាយបក្សី ដែលគេស្គាល់ថាជាជំងឺផ្តាសាយបក្សី H5N1 ឬ HPAI គឺជាការឆ្លងមេរោគដែលប៉ះពាល់ដល់សត្វស្លាប ប៉ុន្តែអាចរីករាលដាលទៅមនុស្ស និងសត្វផ្សេងទៀត។

**ការផ្ទុះឡើងនៃជំងឺផ្តាសាយបក្សីកំពុងសម្លាប់សត្វស្លាបព្រៃ ជាពិសេសសត្វក្ងាន និងទា និងបសុបក្សីដូចជាមាន់ និងមាន់បារាំង។ ជំងឺផ្តាសាយបក្សីក៏កំពុងរីករាលដាលយ៉ាងឆាប់រហ័សចំពោះសត្វគោចិញ្ចឹមយកទឹកដោះ និងអាចប៉ះពាល់ដល់សត្វផ្សេងទៀតផងដែរ។**

**ជំងឺផ្តាសាយបក្សីរីករាលដាលនៅពេល៖**

- **បក្សីដែលឆ្លងមេរោគបានបញ្ចេញមេរោគនៅក្នុងទឹកមាត់ សម្បោរ និងលាមករបស់ពួកវា។**
- **នៅពេលដែលសត្វ និងមនុស្សប៉ះពាល់ជាមួយសត្វស្លាបដែលឈឺ ងាប់ ឬរងរបួស និងវត្ថុរាវរបស់ពួកវា។**

**H5N1 ត្រូវបានរកឃើញនៅក្នុងទឹកដោះគោឆៅ និងចំណីឆៅមួយចំនួនរបស់សត្វចិញ្ចឹម។**

**ប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកប្រសិនបើកូនរបស់អ្នកមានចេញរោគសញ្ញា និងបានប៉ះពាល់ជាមួយសត្វព្រៃ ឬសត្វដទៃទៀត ឬបានទទួលទានទឹកដោះគោឆៅ ឬឈីសឆៅ និងមានចេញរោគសញ្ញា។**

## រក្សាសុវត្ថិភាព

ចៀសវាងការទៅកសិដ្ឋានចិញ្ចឹមបសុបក្សី ផ្សារលក់បក្សី ឬកន្លែងផ្សេងទៀតដែលចិញ្ចឹម រក្សាទុក ឬលក់បសុបក្សីរស់ ប្រសិនបើអាចធ្វើទៅបាន។ ពន្យារពេលទៅទស្សនាសួនសត្វចិញ្ចឹមផងដែរ។

សត្វស្លាបអាចផ្ទុកមេរោគ H5N1 ទោះបីជាពួកវាមើលទៅមិនឈឺក៏ដោយ។

## បន្តតាមដានព័ត៌មាន

នេះគឺជាការផ្ទុះឡើងដែលកំពុងកើតរីងៃ។ វាជារឿងសំខាន់ក្នុងការបន្តតាមព័ត៌មានបច្ចុប្បន្នភាព និងកាផ្លាស់ប្តូរថ្មីៗ។

**ដើម្បីស្វែងយល់បន្ថែម សូមចូលទៅ គេហទំព័រ៖**
**bit.ly/BirdFlu2025**។

## រោគសញ្ញានៃមេរោគ H5N1

- ជំងឺភ្នែកក្រហម ឬភ្នែកឡើងក្រហម
- គ្រុនក្តៅ (លើសពី 98.6 °F)
- ក្អក
- ពិបាកដកដង្ហើម
- ឈឺទ្រូង
- ឈឺសាច់ដុំ ឬអស់កម្លាំង
- ហៀរសម្បោរ ឬតឹងច្រមុះ
- ឈឺក



# តើមជ្ឈមណ្ឌលអប់រំកុមារតូចៗ និងអ្នកថែទាំអាចបង្ការការរីករាលដាលនៃមេរោគ H5N1 យ៉ាងដូចម្ដេច?



- ណែនាំកុមារកុំប៉ះសត្វស្លាបព្រៃ មាន់ ឬសត្វផ្សេងទៀត ជាពិសេសនៅកន្លែងផ្សេងៗដូចជាសួនសត្វ កសិដ្ឋាន ទីតាំងពិព័រណ៍ ឬកម្មវិធីសាលារៀន។ **សត្វស្លាបព្រៃអាចផ្ទុកមេរោគ H5N1 ទោះបីជាពួកវាមើលទៅមិនឈឺក៏ដោយ។**



- ដាស់តឿនកុមារ និងអ្នកថែទាំឱ្យចៀសវាងការទទួលទានអាហារ និងភេសជ្ជៈ ការបញ្ចុកអាហារកុមារ ខាំក្រចក ឬប៉ះមុខរបស់ពួកគេនៅតំបន់ដែលសត្វរស់នៅ។



- ត្រូវប្រាកដថានរណាម្នាក់ដែលប៉ះសត្វលាងដៃជាមួយសាប៊ូ និងទឹកភ្លាមៗ។




- មិនត្រូវទទួលទានទឹកដោះគោមិនទាន់សម្លាប់មេរោគ ឬទឹកដោះគោឆៅ ញ៉ាំឈីសឆៅ ឬញ៉ាំផលិតផលធ្វើពីទឹកដោះគោឆៅឡើយ។
  - ចម្អិនសាច់បសុបក្សី ស៊ុត និងសាច់គោឱ្យបានឆ្អិនល្អ។

**រាយការណ៍ពីសត្វស្លាប ឬសត្វដែលឈឺ ឬងាប់ទៅកាន់គណៈកម្មាធិការអភិរក្សសត្វព្រៃនៃរដ្ឋ Pennsylvania (833-PGC-Hunt) ការិយាល័យសុខភាពសត្វ និងសេវាកម្មរោគវិនិច្ឆ័យរដ្ឋ PA (717-772-2852)**

**ស្វែងរកការព្យាបាលប្រសិនបើកូនរបស់អ្នកមានចេញរោគសញ្ញាដូចជំងឺផ្ដាសាយ ដូចជាភ្នែកក្រហមជាដើម និងបានប៉ះពាល់ជាមួយសត្វផ្សេងៗ។**